# ការសំភាសន៍ជាលើកទី២របស់អ្នកមីង ប៊ុន ភាព

កៈ អ្នកដែលសំភាសន៍ញ៉ែម សុគន្ធា ខៈ អ្នកដែលត្រូវគេសំភាសន៍ឈ្មោះប៊ុន ភាព

## ការសង្ខេបលើកទី២របស់អ្នកមីង ប៊ុន ភាព

នៅក្នុងការសំភាសន៍ជាលើកទី២អ្នកមីងបានរៀបរាប់ពីជីវិតរបស់គាត់ ពេលនៅក្នុងរបបសង្គ្រាមប៉ុល ពត ថាគាត់មិនសូវពិបាករឿងហូបចុកប៉ុន្មានទេព្រោះមានបងប្អូនជាមេកងនៅក្នុងជំនាន់នោះ ហើយតែគាត់ក៏នៅតែបានឃើញពីភាពសាហាវរបស់ពួកឆ្លបក្នុងការនាំប្រជាជនយកទៅសម្លាប់ចោលដោយចងទាំងខ្សែទាំងខ្សែបណ្តើរយកទៅសម្លាប់ចោល ហើយគាត់ថានៅពេលនោះមានពូនោះបានគេយកទៅសម្លាប់ដោយវ៉ៃទំលាក់ទៅក្នុងរណ្តៅ ហើយគាត់ក៏ធ្វើពុតជាស្លាប់ហើយដល់ពេលពួកមេកងទៅបាត់គាត់បានវាឡើងពីរណ្តៅវិញ !!ទិដ្ឋភាពនេះគឺគួរអោយសែនខ្លោចផ្សារណាស់ ពួកវាយកជីវិតមនុស្សជាការលេងសើច ធ្វើអោយគេឈឺចាប់រងទុក្ខជាច្រើន។ អ្នកមីងបានរៀបការហើយគាត់មានកូន៣នាក់ ហើយក្រុមគ្រួសាររស់នៅដោយសុខសាន្តដោយសារស្វាមីមិនចេះផឹកស្រាហើយមើលថែស្រលាញ់ប្រពន្ធកូន។

កៈ អូខេអ៊ីចឹងអរគុណអ្នកមីងសំភាសនអោយញ៉ុមសំភាសន៍ថ្ងៃនេះញ៉ុមឈ្មោះញ៉ែម សុគន្ធាជាអ្នកសំភាសន៍អំពីជីវិតអ្នកមីងនៅក្នុងថ្ងៃនេះជាលើកទី២ ដោយសារពេលមុន អ្នកមីងអត់សូវបានប្រាប់ពីជីវិតខ្លួនឯងផ្ទាល់ទេ ភាគច្រើនតែភាគច្រើនតែពីដូនតា ហើយនិយាយគ្នាបែកអូរហូរស្នឹងមីងណោះ??អូខេអ៊ីចឹងពួកយើងសំភាសន៍គឺនៅស្រុកកៀនស្វាយ ខេត្តកណ្តាល ហើយពួកយើងសំភាសន៍គឺនៅក្នុងខែកុម្ភៈ ឆ្នាំ២០១៨។ អ៊ីចឹងអ្នកមីងចង់សួរពីការសិក្សារបស់អ្នកមីងមុនសិនចុះ អ៊ីចឹងអ្នកមីងបានរៀនអក្សរខ្មែរយើងដល់ថ្នាក់ទីប៉ុន្មានដែរអ្នកមីង?

ខៈថ្នាក់ទី៨យើងប្រលងឌីផ្លូមនោះចុះ!!

កះចាំ បន្ទាប់ពីប៉ុល ពតហើយរៀន ឬក៏មុនប៉ុល ពតហ្នឹងពេលរៀនហ្នឹង?

ខះ ចុះយើងប៉ុល ពតហើយហ្នឹង មុនប៉ុល ពតយើងម៉េចបានរៀន។

កះចាំ!!គិតតែពីសង្គ្រាមរហូតបានអត់បានរៀនមែនទេអ្នកមីង?

ខះហ្នឹងហើយ។

កះចាំ!!

ខះយើងមិនរៀន។

កះចាំអ៊ីចឹងអ្នកមីងពេលរៀនអ្នកមីងរៀននៅសាលាបឋមសិក្សាណាដែរ?

ខះបឋមសិក្សាសោម អក។

កះ សោម អក??

ខះសោម អក។

កះនៅតានីទូកមាសហ្នឹងដែរមីងហេ??

ខះអត់ទេអូន គេនៅតានីទូកមាស យើងនៅទូកមាសយើងនៅខាងកើតណោះ!!

កះហ្ហូំៗ!!

ខះយើងនៅទូកមាសខាងកើតណោះ!!

កះចាំអ៊ីចឹងអ្នកមីងការសិក្សារបស់អ្នកមីងហ្នឹងរៀនបានដល់ថ្នាក់ទី៨
បានជិតប្រលងឌីផ្លូមហើយហ្នឹង!!

ខះប្រលងឌីផ្លូមហើយហ្នឹង ប្រលងនៅទូកមាសអូន!!

កះហ្ហូំ!!

ខះប្រលងយកកៅអីហាំ!!

កះចាំ!!ខះអឺបានចប់ឌីផ្លូម កៅអីអឺអត់ជាប់ទេ។កះហ្ហ៎!!ខះអត់ជាប់ឌីផ្លូមទេ។

កះហើយអ្នកមីងមូលហេតុអីបានធ្វើអោយអ្នកមីងបញ្ចប់ការសិក្សា?

ខះចុះយើងប្រលងជាប់ឌីផ្លូមកៅអីយើងមានលុយកាក់អោយគេបានយើងជាប់!!

កះហ៊ីៗ!!

ខះកាលហ្នឹង១៥០០ហាំ!!

កះចាំ!!

ខះលុយជំនាន់១៥០០ថ្លៃណាស់។

កះហ៊ីៗ
បែកពីសង្គ្រាមហ្នឹងមកមីងណោះ??ចាំអឺចឹងអ្នកមីងសំរាប់មនុស្សម្នាក់ៗសុទ្ធតែមានក្តីស្រម៉ៃរៀងៗខ្លួនក្នុងជីវិតពេលមុនរៀនអឺចឹងអ្នកមីងហាំ!!អឺចឹងពេលមីងនៅក្មេងមីងស្រម៉ៃចង់ធ្វើអីដែរពេលធំឡើងហាំ!!ពេលកំពុងរៀនអីអឺចឹង។

ខះចង់តែរៀនទេអូន យើងរៀនមិនចេះមិនដឹងធ្វើម៉េចយើងប្រលងធ្លាក់
ចង់បន្តដែលហ្នឹងហាំដល់ពេលនេះខ្ជិល
យើងចង់រៀនធ្វើអីបើពេលយើងធ្វើការយើងបានតិចតួច ឈប់រៀនទៅ។

កះចាំ!!

ខះឈប់រៀនធ្វើស្រែចំការទៅ។

កះ អឺចឹងពេលហ្នឹងបើមីងតទៀតអ្នកមីងក៏បានធ្វើការងារអី!!

ខះចង់ត បឹម ដូចថាឪពុកម្តាយយើង អត់មានអ្នកណានៅជាមួយឪពុកម្តាយយើងអឺចឹង
បងៗយើងទៅកោះកុងទាំងអស់នៅតែយើងតែម្នាក់ឯង ធ្វើម៉េច!!

កះចាំ!!

ខះនៅឪពុកម្តាយយើងចាស់ៗ។

ក៖ហ្នឹងហើយ អ៊ីចឹងអ្នកមីងពេលដែលអ្នកមីងកំពុងរៀនហា
អ្នកមីងមានមិត្តភក្ដិដែលជិតស្និតនៅសាលាអីអត់
នៅរាប់អានគ្នាទល់សព្វថ្ងៃហ្នឹងហាំ?មានដែរមីងណោះ?

ខ៖មានតើ មានឥឡូវវាមករកស៊ីនៅភ្នំពេញអស់
ធ្វើមេការមេអីគេធ្វើសំនង់ធ្វើអីនៅភ្នំពេញអីអស់ហើយ។

ក៖ហ្ហ៎!!ហើយគាត់ឈ្មោះអីគេដែរអ្នកមីងមិត្តភក្តិជិតស្និតជាងគេ?

ខ៖ ឈ្មោះវន។

ក៖ មីងវន!!ចាំ!!ហ្នឹងហើយ
អ្នកមីងសិក្សាភាគច្រើនការសិក្សាពេលហ្នឹងអើរដូចរបៀបថាបានខ្ពស់នឹងគេដែរអត់
ដូចរបៀបថានៅក្នុងថ្នាក់មានល្អ មធ្យម ខ្លាំង អីវ៉ាន់អ៊ីចឹងហាំ??

ខ៖បានមធ្យមៗអូនបានលេខ២ លេខ៣អី។

ក៖មីងហាំ អាលេខ២
លេខ៣ហ្នឹងហាមិនមែនមធ្យមទេណាស់អាហ្នឹងខ្លាំងហើយណាស់!!គឺថាខ្លាំងហើយ។

ខ៖អត់ទេ រៀនឈ្លោះតែជាមួយគ្រូទេ។

ក៖ម៉េចវិញមីងប្រាប់បន្តិចមើល??

ខ៖ចុះយើងសរសេរអក្សរ កំពុងតែសរសេរអ៊ីចឹងគ្រូនៅពីក្រោយយោកជើងនៅហ្នឹង
ឈ្លោះតែជាមួយគ្រូ។

ក៖ម៉េចអ៊ីចឹងវិញមីងចាំចេះតែរ៉ៃអ៊ិចឹង?

ខ៖គាត់ចេះតែលេងសើចជាមួយយើងអ៊ីចឹងទៅ!!

ក៖ហ្ហ៎!!

ខ៖ដល់ពេលយើងក្រទៅអីវ៉ានអ៊ីចឹង កុមារនេះសរសេរតុអ៊ីចឹងក្រោមតុសរសេរស្នេហាអីៗ
ទៅដល់ជេរព្រោវៗ!កាចណាស់ញ៉ុមរៀន!!

កៈចំ អឺចឹងគ្រូលួចស្រលាញ់សិស្សមីងហោ?

ខៈហ្នឹងហើយ ប៉ុន្តែទិញសៀវភៅមួយប៊ិចមួយអត់អត់អស់សោះ
ជំនាន់ហ្នឹងអត់មានដែលទិញបានប៊ិចមួយសៀវភៅមួយមានតែគ្រូអោយប្រពន្ធគ្រូអោយគ្រូអោ
យ ។

កៈហ្អ៎!!

ខៈចុះគ្រូជំនាន់មុនស្រលាញ់សិស្សណាស់!!យកសិស្សដែរតើ!!

កៈហ្អ៎!!

ខៈគ្រូភាព គ្រូយន់យកសិស្ស ដល់ពេលញុំមថាយ៉ាៗ។ ឡើងលេងលើគោអឺវ៉ាន់ហ្នឹង
ថាសប្បាយណាស់ពេលហ្នឹង។

កៈមែនហ្នឹងសប្បាយមែនហ្នឹង រៀនដល់ពេលរៀនចប់
ដល់ពេលមីងដល់ពេលអត់បានរៀនទៀតមានអារម្មណ៍ថានឹកសាលាទេមីង?

ខៈនឹកចេះនឹកហើយ ឃើញមិត្តភក្តិរៀន ធ្វើម៉េចបើយើងនៅឪពុកម្តាយយើងនៅ
បងៗយើងចេញមកអស់មកកោះកុងអស់ហើយ។

កៈចា៎!!

ខៈកាលជំនាន់ហ្នឹងមាសមួយជីតែ៣០០០០ទេណាស់មាស១ជីមួយគ្រួសារយើងហា៎!!ជិះទូក
ទៅមួយយប់មួយថ្ងៃ។

កៈពួកគាត់ទៅកោះកុងធ្វើអីគេវិញមីង?

ខៈរកស៊ី ប្តីគាត់ធ្វើការ។

កៈអឺចឹងគ្រាន់តែទៅខាងសំណង់ទេមិនមែនទៅខាងសមុទ្រណាមីងហោ??ទៅរកស៊ីនេសាទអឺ
ណាហី??

ខៈហ៊ឺ??

កះបងប្អូនអ្នកមីងហាំ??

ខះគាត់នៅខាងសមុទ្រអូន។

កះខាងរកនេសាទដែរដូចមីងពេលមុនហេ??

ខះ ហ្នឹងហើយ។

កះហ្នឹងហើយ អ៊ីចឹងអ្នកមីងឥឡូវចូលដល់ប្រវត្តិស្នេហារបស់មីងវិញម្តង
ជាមួយស្វាមី!!!មីងរៀបការជាមួយស្វាមីគាត់ឈ្មោះអីគេដែរអ្នកមីង?

ខះ ស្តើង ៣។

កះស្តើង ៣?

ខះស្តើង ៣។

កះចាំ!!អ៊ីអ្នកមីងអ្នកមីងរៀបការជាមួយគាត់តាំងពីឆ្នាំណាមកវិញ?

ខះ មិនដឹងឆ្នាំណាទេភ្លេចហើយនេះ។

កះប៉ុន្មានឆ្នាំហើយរៀបការជាមួយគ្នា?

ខះអើរ ហ៊ីច្រើនហើយអូនឥឡូវកូនប៉ុន្មាន១៧ ១៨ហើយ។

កះហ្ហ៎!!

ខះកូន១៦ហើយមីងបង!!

កះចាំ បែកប៉ុល ពតមកប៉ុន្មានឆ្នាំមកបានអ្នកមីងរៀបការ?

ខះ២០ឆ្នាំ!!មកនេះ!!

កះដូចប៉ុន្មានឆ្នាំពីប៉ុល ពតមកហាំ??មីងអាយុ២០ឆ្នាំរៀបការអ៊ីចឹងហេ??

ខ៖ហោអត់យូរទេ !!ដល់អាយុ៣០!!មីងហាំនឹងអ៊ំបង្ខំទេ
នៅឯកោះកុងហ្អ៎ថៅហ្វាយនៅកោះកុងនេះ លក់ដូរនៅកោះកុងនៅមុខរោងកុន សប្បាយ
ដល់ពេលអ៊ំហាំ ការក្មួយអញងាប់ងាប់ទៅមែនការបានប៉ុន្មានថ្ងៃគាត់ស្លាប់មែន។

ក៖ហ៊ឺអោយតែបាននៅការក្មួយ?

ខ៖អោយតែបាននៅការក្មួយ។អត់ចង់យកទេអាហ្នឹងចាស់ៗបង្ខំទេ។

ក៖ចាំ!!

ខ៖គេនិយាយតាំងពីអាយុ១៨។ក៖ហ៊ឺៗ!!ខ៖ប្ដីតែ២៥ទេ ឆ្នាំឆ្លូវ!!

ក៖ប្ដីរបស់មីងហ្នឹងហោ?

ខ៖ហ្នឹងហើយ។

ក៖ហើយដល់មីងអាយុ៣០ឆ្នាំ?

ខ៖៣០ឆ្នាំការ។

ក៖ហ្អ៎ តែគាត់ស្រលាញ់មីងណាស់មីងណេះ?

ខ៖ស្រលាញ់តើ!

ក៖ អ៊ីចឹងមីង!!

ខ៖ស្រលាញ់បាត់មុខមិនបាន។

ក៖ហ៊ឺ ចឹអ៊ីចឹងបានមកតាមដល់ណេះ?

ខ៖ ហ្នឹង ប៉ុនការងារមិនអោយធ្វើផង!!

ក៖អូយ អ៊ីចឹងស្រលាញ់គ្នាយូរឆ្នាំហើយនៅតែអោយតែមីងស្រណុករហូត។

ខ៖ហ៊ឺ ចុះបងអើយប្ដីប្រពន្ធកុំអោយតែចេះផិតបានហើយជឿទេ!!

ក៖ហ្នឹងហើយ។

ខ៖អោយតែរកស៊ីស្មោះត្រង់ជាមួយគ្នាគេចោលយើង ចាស់ក៏គេមិនចោលយើងដែរ។

ក៖មានអីប៉ុន្នានទេមីង បងប្អូនគ្នាតែប៉ុន្នានឆ្នាំសោះហ្នឹង មីង៣០ពូការ២៥។

ខ៖អោយតែស្រលាញ់យើងកុំស៊ីលួចលាក់ប្តីប្រពន្ធបានហើយ
ប្តីញ៉ុមអោយតែលុយនេះអីវ៉ាន់លុយបើកមកបារអោយអស់ហើយ
លុយបើកមកអោយអស់ៗហើយមិនចេះទុកទេ។

ក៖ល្អណាស់មីងពូអ៊ិចឹង!!

ខ៖អត់ចេះហូបស្រាទេ ហូបអីទេនោះ!!នោះពាក់មួកសរនោះ!!

ក៖ណា?

ខ៖ខាងកើតគេ។

ក៖ហីបានប្តីក្មេងទៀតណាស់!! ប្តីមីងក្មេង ហើយអោយប្រពន្ធស្រណុកទៀត!!

ខ៖ ថាអោយដេកបន្តិចអីវ៉ាន់ហ្នឹងហើរសប្បាយអីទៅមើលគេហ្នឹង ខ្ជិល ធ្វើមើលឯងក្មេង
ស្រលាញ់ប្រពន្ធណាស់។

ក៖មីងបានប្តីសង្ហាហេ!!

ខ៖មួយៗបង្អាប់ហ្អែង!!ស្រលាញ់ប្រពន្ធ ណាស់ មិនបាច់ស្រីណាទៅកែបានសោះ!!

ក៖អ៊ីចឹងប៉ុន្នានកូនជាមួយពូកូន៧នាក់?

ខ៖៣នាក់ទេ។

ក៖៣នាក់ហេ??អ៊ីចឹងកូនអ្នកមីងសរុបទាំងអស់តែ៣នាក់ហ្នឹងទេហេ??

ខ៖៣នាក់ហ្នឹងស្រី២ប្រុស១។

ក៖ចាំហ្នឹងហើយ!!អញ្ចឹងមិញច្រឡំទេ។
អ៊ីចឹងមីងតើការរៀបការរបស់មីងហ្នឹងស្រលាញ់គ្នាដោយចិត្តឯងឬក៏ឪពុកម្តាយជាអ្នកបង្ខំ?

ខះស្រលាញ់គ្នាចិត្តឯង។

កះចិត្តឯងទេអីចឹងហោ??អ្នកមីងមុនដំបូងឃើញប្តីហ្នឹងនៅឯណាវិញ អ្នកស្រុកជាមួយគ្នាឬក៏ម៉េចដែរ?

ខះ ជីដូនមួយឯង !!

កះហ៊ឺ!!!

ខះមួយនៅភូមិអង្គមីលី មួយនៅភូមិត្រពាំង។

កះសុទ្ធតែជីដូនមួយគ្នាទេអីចឹងហោ?

ខះហ្នឹងហើយ។

កះហោដូចញ៉ុមទៀតហើយ!!

ខះនិយាយឪវាអត់ដឹងទេណាស់ ដល់ពេលយើងការហើយបាននិយាយប្រវត្តិរូបបងប្អូនឯង ប៉ះបងប្អូនឯង បងប្អូនឯងដឹងអីចឹងអញមិនយកទេវ៉ៃ។

កះមីង ពុកម៉ែញ៉ុមបងប្អូនជីដូនមួយគ្នាដែរតើមីង  ហ៊ឺមីងឯងដូចញ៉ុមច្រើនម្ល៉េះ??

ខះមែនដឹងថាការហើយបានដឹងជីដូនមួយឯង ដឹងតែជីដូនមួយឯងដឹងអីចឹងអញមិនយកទេ ដល់ពេលញ៉ុមហ្នឹងហាំអាថ្ងៃធ្វើម្ហូបហ្នឹងហាំ!!!ធ្វើម្ហូបអីចឹងដល់ពេលនេះគេបាត់ញ៉ុមនោះដល់ពេលហ្នឹងញ៉ុមចង់ទៅមើលឃើញយាយទួតនោះ ទៅយាយទួតយំពេកដល់ហ្ហ៎ដល់ពេលហ្នឹងពួកហ្នឹងគេឆោលោររកញ៉ុម ខ្លាចញ៉ុមមិត្ត។

កះចាំ!!

ខះឃើញឃើញនៅផ្ទះម៉ែក្មេក។

កះចាំ!!មីងដំបូងឡើងមកជួបគ្នានៅឯណាជាមួយស្វាមី?ខះចាំ??កះជួបគ្នាដំបូងហាំ?

ខះចាស់ៗដឹកនាំមកអូន។

កះហ្ហ៎ហើយដល់ពេលអីចឹងមកក៏ចាប់ផ្តើមស្រលាញ់គ្នាអីចឹងទៅ?

ខ៖ចាប់ផ្តើមស្រលាញ់គ្នា។

ក៖ចាស់ៗនែនាំគ្នាសិនបានស្រលាញ់គ្នាពេលក្រោយ?

ខ៖ហ្នឹងហើយ។

ក៖ឃើញចេះតែ!!

ខ៖ចាស់ស្រលាញ់គ្នាទៅ
ដល់ពេលនេះអត់ដឹងញ៉ុមការឯណាដល់ពេលការហើយដល់តែលក់ដុរអញ្ចឹងទៅ
ដល់ពេលនេះហើយគេដឹងញ៉ុមការទៅដល់ពេលអ៊ំនេះថាហ្បែងតិចត្រូវរបស់គេ
ដល់នេះអាមួយហ្នឹងវាឃំហាំ កូនពេទ្យហាំ!!

ក៖ចាំ!!

ខ៖ដល់ពេលញ៉ុមការហើយអ៊ីចឹងគេអោយឪគេមកចូលនិយាយ អត់ទេញ៉ុមការហើយហើយ
!!បានជឿហ្វំ!!

ក៖ហ្វំ!!

ខ៖ហើយវារៀននៅទូកមាសហើយញ៉ុមការហើយវាអត់ដឹងញ៉ុមការហើយហើយ។

ក៖មានអ្នកលួចស្រលាញ់មីងណោះ?

ខ៖ហ្វ!!មិនខ្វះទេបង យើងកូនម្នាក់ឯងយើងនៅម្នាក់ឯងហាំ!!

ក៖ចាំ!!

ខ៖គេចង់បានគ្រប់គ្នា!!

ក៖ហើយដល់ពេលហើយជាមួយនឹងពូបានកូនប៉ុន្មាននាក់ដែរ?

ខ៖៣នាក់អូន។

ក៖គាត់ស្រីប៉ុន្មានប្រុសប៉ុន្មានដែរ?

ខ៖ស្រី២ប្រុស១។

ក៖មីងអាចនិយាយប្រាប់ឈ្មោះកូនមីងទាំងអស់មើលឈ្មោះអីគេខ្លះ?

ខ៖ អើរឈ្មោះឡូយណាស់អូន!!

ក៖ឡូយហ្នឹងម៉េចទៅមីង?

ខ៖កូនទី១ ឈ្មោះ នូ ចន្ទ្រា ។

ក៖ចាំទី២?

ខ៖កូនទី២នូ សិលា ។

ក៖ចាំ!!

ខ៖កូនទី៣ នូ ចាន់វុធ។

ក៖នូ ចាន់វុធ !!

ខ៖ នូ ចាន់ វុធ។

ក៖ហ៊ឺឈ្មោះពិរោះៗមែនហ្នឹងហាំមីងណាស់!!អ៊ីចឹងអ្នកមីងមិញអត់ទាន់និយាយអំពីប្រវត្តិប្ដីតែគ្រាន់តែចាស់ៗដឹកនាំអ៊ីចឹង មុនការជាមួយគ្នា៦ហ្នឹងមានយល់ចិត្តគ្នាអីវ៉ាន់សិនទេ?

ខ៖ហ៊ឺចុះយើងបើមិនយល់គ្នាមិនយកកើតអូន!!

ក៖មើលចិត្តគ្នាប៉ុន្មានខែបានរៀបការអ្នកមីង?

ខ៖៦ថ្ងៃអូន។

ក៖ប៉ុន្មាន?

ខ៖៦ថ្ងៃដាក់ថ្ងៃការ ទុកធ្វើអី!!

ក៖ស្មានតែមើល!!មិញនិយាយទ្រង់រៀងហាំណាស់ ស្មានតែត្រឹម២ ៣ឆ្នាំអីវ៉ាន់ទៅ !!៦ថ្ងៃ។

ខះតែតែ៦ថ្ងៃទេ!! ជាមួយអឺ៦ថ្ងៃ បើប្អូនតែ៥ថ្ងៃផង។

កះហ្អ៎!

ខះបងនោះ៥ថ្ងៃដូចគ្នា។

កះចាំ!!

ខះញុំម៦ថ្ងៃ។

កះចាំហើយស្រលាញ់គ្នាទល់តែឥឡូវហ្នឹងទៅ?

ខះហ្នឹង។

កះហ៊ឺឡូយណាស់មីងហា!!
អូខេអឺចឹងអ្នកមីងសំរាប់ចូលដល់ជីវិតអ្នកមីងវិញម្តងដោយសារអ្នកមីងកើតមកចំពេលសង្គ្រាមដែរហ្នឹងមែនទេមីងហេ?

ខះចំអូនយើងនៅមណ្ឌលកុមារ។

កះម៉េចវិញមីងនៅមណ្ឌលកុមារហ្នឹងម៉េចវិញទៅ អូនឯងអត់ទាន់ផងអូនឯងទឹមអាយុជាង២០២០ឆ្នាំនៅ?

កះឥឡូវទឹម២០ឆ្នាំជាងហ្នឹង។

ខះហ្អ៎អឺទាន់ហើយអូន។

កះមើលនិយាយពីប្រវត្តិហ្នឹងបន្តិចមើលមីង?

ខះអត់សូវដឹងដែរ !នៅមណ្ឌលកុមារអឺចឹងដល់ពេលអិចឹងយើងមិនរត់ពីអាពតអូនណោះ??

កះហ៊ឺៗ!!

ខះហ្នឹងហើយរត់ពីអាពតហ្នឹងមកមានអីគេទៀត។

កះម៉េចទៀត?

ខះដល់ពេលអាយើងមកវិញមក!!

កះការរស់នៅក្នុងមណ្ឌលហ្នឹងម៉េចដែរមីង?

ខះវេទនាដែរហ្នឹងហាំ។

កះពេលហ្នឹងនៅក្នុងជំនាន់ប៉ុល ពតហើយមីងហោ??

ខះជំនាន់ប៉ុល ពតហើយអូន។

កះម៉េចវិញទៅមីង ឥឡូវមីងអាចនិយាយពីជីវិតរបស់មីងនៅក្នុងជំនាន់ប៉ុល ពតតើមីងជួបរឿងជូរចត់អីគេខ្លះ?

ខះជូរចត់មីងអើរ មីងវាមិនសូវពិបាប៉ុន្មានទេអូន ត្រូវបានស្មើខោអាវអីចឹងទៅបានត្រូវកន្សែងកន្សែងអីចឹងទៅមីងអើរមានកូនធ្វើទ័ព បងសក្តិពាធ្វើការអីហ្នឹងអូន។

កះនៅក្នុងជំនាន់?

ខះនៅជំនាន់យើង ជំនាន់អាពតហ្នឹងបងធ្វើការឃើញទេជំនាន់ហ្នឹងកូនធ្វើទ័ពកូនអើរឪពុកម្តាយយើងនៅរស់ទេណាស់។

កះចាំ!!

ខះអើរអត់នេះយើងអត់នៅអីចឹងពួកថ្មីពួកចាស់ តែពួកថ្មីគេយកវ៉ៃចោលហើយសល់តែពួកចាស់ឃើញទេ!!ជំនាន់ហ្នឹងយើងថាពួកយួនហ្នឹងវាមិនបុកចូលមកវាមិនអោយគេយើងហ្នឹងអ្នកមេអី មេភូមិមេអីគេមិនអោយស៊ីនំបញ្ចុក ឃើញទេធ្វើនំបញ្ចុកអោយស៊ីហើយងាប់ វាមិនទាន់ងាប់ណាអូនមិនទាន់បានស៊ីផងយួនមិនបុកមកយើងមិនមិត្ត។ឃើញទេ!!

កះហោងហើយ!!

ខះជំនាន់ហ្នឹងហាំ!! ហោងហើយអូនកុំអីងាប់ខ្ទេចខ្ទីនៅតែកូនធ្វើទ័ពទេ នៅតែគ្រួសារនៅអង្គមីលីនៅតែគ្រួសារ៣នាក់ទេ នៅអី នៅពូឈួននៅអីហ្នឹងហោ អ៊ុក ៣ចហ្នឹងទេខ្លាំងមានកូនធ្វើទ័ពឃើញទេ កូនមានធ្វើទ័ពពីរនាក់ ហើយកូនស្រីហ្នឹងសក្តិ៣ហ្នឹងទៀតអីគេឃើញទេ!!ស្រណុកមាំណាស់អូនជំនាន់អាពត ។

កះហ៊ឺហោងហើយមីងណែ!!

ខះហើយដល់ពេលបងញ៉ុមកងចល័តឃើញទេទៅអីចឹងទៅធ្វើការនៅហ្នឹងពេលមកផ្ទះម្តងៗទៅបានត្រសក់ទុំបានចំនីចំណុកយកទៅអីចឹងមេកងគេស្រលាញ់គេអត់អោយធ្វើការអីទេឃើញទេ!!សព្វថ្ងៃហ្នឹងមក ដល់ពេលអីចឹងទៅពួក ចុះឃើញអញ្ចឹងយើងមិនទៅរកម្ហូបដល់ពេលអញ្ចឹងឃើញទេពេលជំនាន់ហ្នឹងយន្តហោះគេទំលាក់គ្រាប់ហើយមែនហោឃើញទេបែកពីឪពុកម្តាយទៅ៣ ៥ខែបានរកឃើញមកវិញអីចឹងទៅតាមទៅតាមទៅចេះតែបានមកស្រុកយើងវិញទៅស្តុមអូនអើរ មិនដឹងស្បែកឆ្អឹងនៅណាទេ នៅរស់សព្វថ្ងៃហ្នឹងទៅ អាយុ៥០ជាងហើយអាយុ៥២។

កះហ៊ឺៗ!!

ខះវេទនាណាអូនអើយដោតទាំងខ្សែទាំងខ្សែហ្វ៊ូ!!

កះមីងឃើញហោ?

ខះឃើញ ឃើញផ្ទាល់ភ្នែក។

កះឃើញម៉េចខ្លះមីង ទិដ្ឋភាពទាំងអស់ហ្នឹងនិយាយមើល??

ខះវេទនាណាស់អូនអើយ!!

កះដឹកមនុស្សទៅវ៉ៃចោល?

ខះដឹងមនុស្សទៅវ៉ៃចោលដល់ពេលគេបាញ់គេទំលាក់គ្រាប់បែកហ្នឹងមកឃើញផ្សេងឃើញទេយើងមិនត្រូវរបួសយើងមិនសែងវិតឃើញទេ!!ថាវេទនាណាស់ កុំនិយាយរឿងហ្នឹងវាអាក្រក់ណាស់។

កះចង់ដឹងវាអាក្រក់ហ្នឹងហាំមីងថាតើវាអាក្រក់ដល់ថ្នាក់ណាទៅ!!

ខ៖ឪពុកម្ដាយអូនឯងមិននិយាយប្រាប់ទេហេ?

ក៖និយាយប្រាប់បានខ្លះៗប៉ុន្តែញ៉ុមចង់ដឹងពីជីវិតមនុស្សផ្សេងទៀតហាំតើអើរដោយសារអើរអ្នកខ្លះគេនៅភូមិផ្សេងៗគ្នាហាំដោយសារគាត់នៅឆ្ងាយ
គាត់នៅបាត់ដំបងហ្នុ៎!!ហើយមីងនៅកំពតនេះណោះហេ អ៊ីចឹងឡើងជើងត្បូង។

ខ៖អើរអូនអើយពួកថ្មីៗគេយកទៅវ៉ៃចោល ទៅស្លូងដកយើងស្លូង
ទៅធ្វើការមិនល្អអីវ៉ាន់ស្លូងៗយូរជាងគេហ្នឹងគេដឹងដៃយកទៅវ៉ៃចោលហើយ។

ក៖អាមិនលឿនក៏វ៉ៃចោលទៀត?

ខ៖ហ៊ឺ
កងចល័តយើងស្លូងមិនលឿនអ៊ីចឹងទៅគេឈរមើលយើងនៅលើភ្លឺហ្នឹងកាំភ្លើងមួយដើមចាំមើលយើងអាស្លូងល្អអាណាមិនល្អហ្នឹង តែយើងស្លូងយូរ ដឹកដៃយើងយកទៅវ៉ៃចោលទៅ។

ក៖វាដូចរបៀបថាហ៊ឺអញអត់មានអីធ្វើអញដើរក្រវេក្រវាអីនេះ??

ខ៖វាដេកហា ដេកនៅលើនេះ
ដូចនៅរោងចក្រយើងធ្វើយើងចង់មិនធ្វើអីស្រុកហ្នឹងអានិតហ្នុ៎!!!កំពតថាវ៉ៃៗហើយ!!

ក៖ដូចវាយកយើងយកជីវិតយើងយកទៅលេងសើចណោះ??

ខ៖យកលេងសើចអីជាមួយយើងទេថាវ៉ៃៗហើយធ្វើការមិនល្អ
ពួកថ្មីដឹងតែយកដាក់ភ្ញសភ្ញសហើយ ។

ក៖ពួកអ្នកដែលជំលៀសមកពីហ្នឹងវិញមកពីណាមីង?

ខ៖ដឹងអាណាដឹងអាពត។

ក៖អត់មានប្រាប់អីទេហេ?

ខ៖ហ៊ឺ!!

ក៖មីងការហូបចុករបស់មីងម៉េចដែរ
មិនមែន៣ឆ្នាំ៨ខែ២០ថ្ងៃហ្នឹងវាស្រួលរហូតឬក៏វាមានថ្ងៃណាខ្លះពិបាក?

ខះវាពិបាកពិបាកកន្លែងណាពិបាកៗកូនគេធ្វើទ័ពគេស្រណុកទៅ
កូនគេណាគេមិនធ្វើទ័ពគេវេទនាទៅបាយបបរ តែពេលនេះគេចែកហើយមួយគុ៧
៨នាក់១០អីអីចឹងហើយមួយជុងៗហើយយើងហូបឆ្អែតដែរយើងបើសិនជាយើងឃើញឪពុកម្តាយយើងមកពីធ្វើការ
ឃើញយើងបានមួយជុងអីចឹងយើងរំលែកអោយឪពុកម្តាយយើងទៅណាស់យើងអានិតឪពុកម្តាយញុំមធ្វើអញ្ចឹង ញុំមមិនដែលហូបបានឆ្អែតឆ្អែតអីចឹង
ដល់ពេលយើងឃើញឪពុកម្តាយយើងអោយម្នាក់មួយចានៗយើងរំលែកអោយឪពុកម្តាយយើង ដល់ពែលយើងកូនយើង ចុះយើងក្មេងមិនក្មេងទូចឃើញទេ!!
ដល់ពេលហ្នឹងជំនាន់ហ្នឹងយើងមិនទារសាច់ឃើញទេ
ម៉ែសាច់ម៉ែសាច់មានណាម៉ែសាច់ម៉ែសាច់គេសំលក់យើងគេយកយើងវៃចោលទៀត ។

កះតែមីងអត់ទារដែរពេលហ្នឹងហោ?

ខះអូនញុំម អូនពៅញុំមទារហាំ ដល់ពេលនេះញុំមបានកូនមេកង បើអត់កូនមេកង
គេយកវៃចោលហ្នឹងអូន បើអត់!!

កះហើយក្មេងគ្នាទៅដឹងអីមីងហើយ?

ខះវាជំនាន់ អូនឯងមើលមើលវាជំនាន់អាក្រក់ណាស់ ពេលនិយាយពីប្រវត្តិរូបហ្នឹង
ឃើញចាស់ៗជំនាន់ដើម
អីទៅភ្នំពេញទៅពិគោះគ្នាភ្នំពេញហ្វំ!!ទៅជំនាន់ហ្នឹងសន្ធឹកសន្ធាប់វេទនាណាស់។

កះ
អើយមីងអើរពិបាកណាស់!ហើយមីងឃើញគេចងខ្សែយកមនុស្សទៅសម្លាប់ចោលហើយមែនទេ?

ខះហ៊ឺ!!

កះតែឃើញគេវៃនៅមុខទេ?

ខះ ហើយចុះគេខ្លាចអីអូនយើងទៅស្ពានដែរហ្នឹងហាំ ស្ពានដែក
ទៅវៃចោលនៅក្នុងព្រៃយើងដេកហ្នឹងគេវៃចោលហ្នឹង
ព្រលឹមឡើងដេកមិនដឹងខ្មោចងាប់អីហ្នឹងៗផង។

កៈអូយ!!មីងភ័យទេ?

ខៈញុំមដើរកន្លង!!។

កៈដើរកន្លងខ្មោងហ្នឹងទៅ?

ខៈហ្នឹងដើរកន្លងខ្មោចនៅក្នុងព្រៃហ្នឹង
យើងដេកហ្នឹងគេរ៉ៃចោលនៅហ្នឹង។កៈចំ!!ខៈព្រលឹមឡើងដេកហ្នឹងមិនដឹងខ្មោចងាប់ហ្នឹង
កុំតែភ័យ។

កៈហើយមីងឮទេ?

ខៈដើរកន្លង។

កៈដើរកន្លងខ្មោចហ្នឹងទៅ?

ខៈដើរកន្លងខ្មោច យើងម៉េចដឹងដើរទៅ
យើងគេរ៉ៃចោលយើងដេកលក់ចុះក្មេងៗយើងពេញលក់ហើយអូន ដេកលក់ហើយ
ដល់ព្រលឹមឡើងឃើញពីរនៅកៀនព្រៃ។

កៈ
អូយ!!ហើយមីងមានដែលដើរទៅណាដើរទៅឃើញប្រទះភ្នែកគេយកមនុស្សយកទៅសម្លាប់
ចោលអីអត់នៅមុខ?

ខៈចេះតែឃើញហើយអូន។

កៈឃើញដែរ?

ខៈឃើញ យើងឃើញទៅយើងញាក់ដឹងធ្វើម៉េចទាំងខ្សែទាំងខ្សែអីចឹងដឹក
!!អីនៅកងចល័តអីចនៅផ្ទះអីពួកកងចល័តទៅផ្ទះនៅផ្ទះអីហ្នឹងអូនអើយ!!វេទនា។

កៈហ៊ឹមីងអើយមីង!!

ខៈដឹកទាំងខ្សែទាំងខ្សែ វាយកទៅរ៉ៃចោលនៅចំការចាមហ្នុំ!!

ក៖ចាម?

ខ៖ចាម ឈ្មោះចំការចាម។

ក៖ហ្ហ៎!!ឈ្មោះគេទេអ៊ីចឹងហេ??

ខ៖ចំការចាមវេទនាណាស់ជំនាន់ហ្នឹង។

ក៖ចាំ!!

ខ៖អោយពួកកំពតនិយាយមើលទឹកភ្នែកទឹកភ្នែកទឹកសំបោរ។

ក៖ហ្ហ៎ភាគច្រើនគេថាពួកនៅកំពត!!

ខ៖ភាគច្រើនពួកថ្មីទៅពួកពីភ្នំពេញទៅគេយកវ៉ៃចោលហ្នឹងតើ!!

ក៖ហ្នឹងហើយ។

ខ៖ជំនាន់ហ្នឹងមើលសួរចាស់ៗមើលថាអ៊ីកុហក!!

ក៖និយាយទៅនៅកំពតគេថាសម្លាប់សាហាវដែរមីងណេះ?

ខ៖អើរ !!ពួកថ្មីពួកអីហ្នឹង ពួកទៅពីភ្នំពេញពួកអីហ្នឹង គេទុកតែពួកចាស់ៗពួកជំនាន់អាពតហ្នឹង ពួកថ្មីគេដឹកយកទៅវ៉ៃចោលអស់ហើយ មិនសូវរស់ទេពួកថ្មី សួរមើលចុះ ផ្ទះណាក៏ដោយផ្ទះណាភូមិណាក៏ដោយភូមិណា ពួកថ្មីពួកចាស់សួរមើលហ្ហ៎!!ថាអ៊ីកុហក។

ក៖ម៉េចអ៊ីចឹងមីងណោះបានក៏ស្អប់អ្នកថ្មីម្ល៉េះ ប្រជាជនឯងដដែលសោះហ្នឹង។

ក៖សួរម៉ាក់អូនឯងមើលម៉េចវិញបានគេយកវ៉ៃចោលវិញហ្នឹង។

ខ៖ធ្វើការល្អធ្វើការមិនល្អតែវាដាក់ចំពួកអាថ្មីអាចាស់ សួរជំនាន់ហ្នឹងមើលទៅបើថាអ៊ីកុហក ចុះគេសំភាសន៍ហ្នឹងមិនឃើញចុះ ផ្តល់ពត៌មានហ្នឹងមិនឮជំនាន់អាពតមើលមើល។

ក៖ចាំហ្នឹងហើយ។

ខ៖គេចាក់មើលមើលទឹកភ្នែកទឹកសំបោរដេញបាញ់កូនឃុំស្រែកម៉េចដឹងហើយ។

កៈគ្រប់កន្លែងអីចឹងតែមួយម៉ងមីងហោ??អត់មានកន្លែងណាជាងអ្នកណាគេទេហោ?សុទ្ធឃើញវេទនាទាំងអស់។

ខៈឃើញវេទនាទាំងអស់ ជំនាន់អាពត ចុះយើងមានអីបានស៊ីគ្រប់គ្រាន់អូនអើយ ដើរកេងចល័តបាយ បបរអីចឹងទៅ ពេលបាយបបរអត់មានស៊ីយើងដើររើសជំឡូងហ្នឹងគេទៅ ដល់ពេលមេកងគេដឹងយើងឡើងលួចបេះដូងគេអីចឹងទៅ គេឃើញគេវ៉ៃយើងអីចឹងទៅ យើងពាក់ករ យើងចងដូងហើយពាក់ខ្សែករបណ្ដើរយកទៅវ៉ៃទៅ!!

កៈចំ!!

ខៈសាហាវណាស់អូនកុំនិយាយាអីចឹង អីចឹងបានថាអីចខ្ជិលនិយាយពីប្រវត្តិរូបណាស់វាអីចឹងវាវេទនាណាស់។

កៈអីចឹងមីងឃើញអ្នក អ្នកណាគេលួចដូង!!បើគេទាន់!!

ខៈអើរចុះជំនាន់ហ្នឹងកងចល័តហ្នឹងមានតែស្បែកហើយនឹងឆ្អឹងគ្នាមិនលួចឡើងបេះស៊ី!!

កៈហ៊ឺ!!

ខៈហើយជំឡូងយើងដើរហើយដកនៅសល់អាប៉ុនមេដៃមេយើងយើងមិនដើររើស យកមកស៊ីយកមកដុតស៊ីតែមេកងឃើញគេមិនវ៉ៃយើងចោល !!

កៈហើយបោះចោលសោះហ្នឹងហា!!!

ខៈអើរបោះចោលហ្នឹងហា៎ គេបោះចោលយើងធ្វើការយើងហេរយើងឡើងមករកស៊ី។

កៈអើយ!!

ខៈដូចយើងដេររោងចក្រអីចឹងយើងដេរមិនទាន់ដល់ម៉ោងអូនឯងចេញមេមិនស្ដី!!

កៈហ៊ឺ!!

ខៈហើយនេះយើងធ្វើការយើងហេរយើងមិនដើររើសអីចឹងស៊ីគេមិនវ៉ៃ ខ្លាំងម្ល៉េះ។

កៈតែបើសិនជាផុតពីហ្នឹងអត់អីទេមីងណេះ?ផុតពីម៉ោង?

ខះអត់អីទេ!!ធ្វើការល្អបាននៅយូរ ធ្វើការមិនល្អគេយកទៅវ៉ៃចោលភូសៗដាក់ជីស្រែធ្វើមិនដឹង!!

កះមីងខ្មោចពេលគេយកទៅវ៉ៃចោលគេយកទៅឆ្ងាយពីភូមិឬក៏ពេលខ្លះនៅហើមពេញស្អុយ!!

ខះងាប់គេយក!!មានអីគេយកទៅសម្លាប់ចោលក្នុងព្រៃនោះ!!

កះហ្ហ៎!!សុទ្ធតែ!!

ខះគេយកសម្លាប់នៅក្នុងព្រៃ អាណាគេធ្វើអោយយើង គេកាប់ជន្លងនៅក្នុងព្រៃអាណាគេវ៉ៃចោលនៅកណ្តាលភូមិយើង យកកៀនៗទៅព្រៃហ្ហ៎!!

កះតែមិនសូវឆ្ងាយណាប៉ុន្មានដែរមីងណោះ?

ខះ ហ្នឹងហើយយកទៅឆ្ងាយៗដែរហ្នឹងអូន!!កាប់អន្លង់កាប់អី នឹងចេះយួនមកបុកចូលដែរបើសិនជាយួនមិនបុកចូលស្មានតែយើងហ្នឹងនៅរស់ហេ??កុំអីមនុស្សងាប់អស់ហើយ!!

កះឥឡូវមីងនិយាយពេលថ្ងៃចុងក្រោយអាពេលដែលថ្ងៃគេហៅហូបនំបញ្ចុកនោះវិញមើលម៉េចទៅមីងថ្ងៃហ្នឹង?

ខះអាថ្ងៃហ្នឹងហា៎ កំសត់តិចហើយថ្ងៃហ្នឹង។

កះឥឡូវនិយាយមើលកំសត់ម៉េចខ្លះទៅ?

ខះឥឡូវយើងកន្លង កន្លងហួសហើយអូន។

កះចា៎!!

ខះយើងបានសប្បាយវិញហើយ។

កះហ្នឹងហើយ តែដល់ពេលថ្ងៃហ្នឹងគេហៅម៉េច គេដឹងថាគេដាក់ថ្នាំបំពុលអីទេ??

ខះដឹងតើ គេដាក់អោយយើងធ្វើនំបញ្ចុកស៊ីហើយ!

កះចុះគេសុទ្ធតែមាន!!

ខះយើងធ្វើស៊ីថ្ងៃហ្នឹង ស្អែកឡើង យប់ឡើងយួនបុកមកថ្ងៃល្ងាចហាំ!!

កះហ្ហ៎!!

ខះថាព្រលឹមឡើងត្រូវបានស៊ីហាំ!!

កះហ៊ី!!

ខះដល់ពេលយួនបុកមកយើងផុតស៊ីទៅ ។

កះតែប៉ុន្តែពេល!!

ខះថាអឺដេកនៅមណ្ឌលកុមារដឹងថាគេអូនអើយថាប្រជាជនមិត្តមកនៅមុខផ្ទះហ្នឹង
បងញ៉ុមថាស្អីទេអ៊ើយអញឃើញយួនឃើញអឺបាញ់គ្នាបាញ់អឺ
បប្អូលគ្នាបែកម៉ែឪអស់រលីង។កះហ៊ី!!ខះមណ្ឌលកុមារបែកម៉ែឪអស់រលីង
ញ៉ុមអឺវ៉ាន់មិត្តទៅម៉ែឪញ៉ុមអឺវ៉ាន់ពេលកំពុងរៀបចំមកផ្ទះដែរ
ខ្លះណាបែកម៉ែឪរកគ្នាមិនឃើញទេ!! មិនដឹងនៅណាអឺណា!

កះហើយប៉ុន្មានថ្ងៃបានរកម៉ែឪឃើញវិញ?

ខះតែមួយថ្ងៃ។

កះតែមួយថ្ងៃទេហោ?

ខះតែមួយថ្ងៃ។

កះគ្រាន់តែបែកខ្មែរអាកំពុងអាយួនចូលមកហ្នឹងហោ??

ខះហ្នឹងហើយ។អើរវេទនាណាស់បាញ់ទូងទូងគ្រាប់កាំភ្លើងអើយ!!

កះអើយរត់ទៅណាស់ទៅមីងហ្អើយ។

ខះអើយវេទនាណាស់អូន!!កុំនិយាយអារឿងហ្នឹងនិយាយរឿងឥឡូវវាសប្បាយ
បើនិយាយពីរឿងជំនាន់ហ្នឹងពិបាកណាស់។

កះមីងនឹកឃើញរឿងមួយហ្នឹងគួរអោយខ្លាចទេមីង?

ខ៖មិនចេះខ្លាចទេ សួរជំនាន់ម៉ែអូនឯងមើល!!ម៉ែឪអូនឯងមើលម៉េចវិញ!!

ក៖ម៉ែខ្លាចដែរ។

ខ៖មកសួរមីងជំនាន់ហ្នឹងទឹកភ្នែកប៉ុន្មាន!!

ក៖មីងអើរយំរាល់តែថ្ងៃហើយមីង។

ខ៖ប៉ុណ្ណឹង
ឃើញមើលកំសត់ណាស់។មើលៗក្នុងនេះមើលកូនក្មេងគេឆែកក្នុងនេះមើលចុះ!!គេដេញបាញ់ម៉ែៗឃើញទេមើលចុះ!!ពេញនេះហ្នឹងចុះ!!អាពតហាំ!!

ក៖ចាំ!!

ខ៖អាពតទេ។

ក៖ អើយមីងមានដែលរួច រត់ចេញពីអាពតហ្នឹងទៅនៅណាអីណី ទៅនៅក្នុងព្រៃក្នុងអីទេមីង?

ខ៖ទៅណាទេអូនរត់ទៅណាវិញទៅ។

ក៖បើទៅណាក៏ជួបអីចឹងដែរមែនទេមីង??

ខ៖ទៅណា មានអ្នកណារត់រួចទេអូន កុំបានយួនហ្នឹងចូលមកកុំអីយើងងាប់អស់ហើយ។

ក៖តែហេងហើយមីងឯងគិតមើលមើលស្អែកឡើងគេដាក់បំពុលនំបញ្ចុកហើយហ្នឹង!!

ខ៖ហ្នឹងហើយ ហើយយើងបានស៊ីនំបញ្ចុកអរណាស់
ហើយពេលហ្នឹងគេកាប់អន្លង់ហើយហើយណាស់។

ក៖ហើយពេលហ្នឹងអត់ទាន់!!។

ខ៖គេកាប់អន្លង់ហើយហើយ។

ក៖អើរកាប់រណ្ដៅទុកមួយអោយហើយ។

ខ៖អើរវាទៅកាប់អន្លង់ហើយហើយអូន កាប់អន្លង់នៅស្រុកគេណាណោះ!!
កាប់ហើយហើយអន្លង់ អាខ្លះធ្វើនំអន្សមជ្រូកវេចនំអន្សមជ្រូកហាំ!!

ក៖ហ៊ឺ!!វាអោយប្រជាជនជួយអត់ឬក៏គ្រាន់តែថាគ្នាវាអ្នកធ្វើហ្នឹងទេ?

ខ៖ពួកយើងហ្នឹង។

ក៖ហូសសប្បាយចិត្តណាស់ពេលហ្នឹងមីងថាពួកអញឆ្អែតហើយ ឆ្ងាញ់ហើយស្អែក។

ខ៖ងាប់អស់ហើយចេះយួនបុកមកបាន យួនបុកមកសំណាងណាស់។

ក៖មីងញ៉ុមភាគច្រើនសំភាសន៍មនុស្សគ្រប់គ្នាភាគច្រើនគេនិយាយថាភាគច្រើនអាហូបនំបញ្ចុកហ្នឹងហ្នុំថាភាគច្រើនអោយតែមុនថ្ងៃហ្នឹងភាគច្រើនមួយៗគឺហូបនំបញ្ចុកគ្រប់គ្នា
សូម្បីតែអ្នកនៅកំពង់ចាមក៏អញ្ចឹងដែរ។

ខ៖តែនំបញ្ចុកហ្នឹងអូន អន្សមជ្រូកនំបញ្ចុក ភូមិយើងនំបញ្ចុក ភូមិគេអន្សមជ្រូក។ក៖ហ៊ឺ!!អើរ!!

ខ៖ម៉េចៗវាខុសគ្នាអូន អាពត។

ក៖ហ៊ឺៗ!!

ខ៖និយាយម៉េចខុសគ្នា។

ក៖មេធំអីវ៉ាន់នៅណាទៅមីងញ៉ុមឆ្ងល់ដល់ហើយនេះ។

ខ៖ហ្នុំមេអាប៉ែតនៅ អាប៉ែតគេចាប់ជាប់គុកហើអី?

ក៖អាពត អាពតងាប់បាត់ហើយប៉ុន្តែ!!

ខ៖អាប៉ែត។

ក៖អ្នកណាគេអាប៉ែតញ៉ុមឈ្មោះ??

ខ៖មេកងអាប៉ែតហាំ អាប៉ែតយើងសព្វថ្ងៃហ្នឹងហ្នុំ!!តាម៉ុក តាប៉ែតហ្នុំ!!

ក៖ហ្នុំ!!

ខ៖អូនឯងដឹងពេទ្យតាកែវអត់?

ក៖អត់។

ខ៖ផ្ទះគេតាម៉ុកតាអីនៅហ្នឹងហា៎!!

ក៖ហ្អ៎!!

ខ៖មេអាពត!!

ក៖ចុះគាត់នៅរស់!!

ខ៖នៅ!!ងាប់បាត់ ដឹងអីគេថាជាប់គុក
យើងមិនដឹងថារស់នៅណាអីណាយើងមិនសូវដឹងថានៅៗៗៗ!!

ក៖នួន ជានៅ។

ខ៖នៅ!!នួនជានៅហោ?

ក៖នៅអាពតស្លាប់។

ខ៖នួន
ជានៅអាម៉ុកអាប៉ែតហ្នឹងដូចងាប់អីជាប់គុកមិនដឹងរួចនៅចុះ?ជំនាន់ហ្នឹងគេចាប់បានតើ!!

ក៖ហ៊ឺអាពួកមេក្លោងធំៗហ្នឹង។

ខ៖អើរអ៊ីចឹងដឹងអាប៉ែតដឹងអាម៉ុកនៅហ្នឹងចុះ?

ក៖តាម៉ុកហើយនឹងតាប៉ែតតែមួយទេអ៊ីចឹងហោ?

ខ៖ហ៊ឺ!!

ក៖តែមួយ!!

ខ៖នៅតាកែវហ្អ៎!!ពេទ្យតាកែវផ្ទះគេនៅប៉ុណ្ណាណភីនៅហ្នឹងហើយចុះ!!

ក៖កូនចៅ!អីវ៉ាន់ម៉េចទៅមីងណោះ?

ខ៖ហ៊ឺ??

ក៖កូនចៅពួកគាត់ម៉េចទៅ?

ខ៖ចុះអាណាទៅដឹង!!។

ក៖ម៉ែឪធ្វើអញ្ចឹង។

ខ៖អូនអើយជំនាន់ហ្នឹងអូនអើយបងហា៎!!ជំនាន់ហ្នឹងចៀនណាងាប់ដែរ
ចាំមើលកងចល័តនៅធ្វើការនៅព្រៃក្រឡាយើង យើងឡើងម៉ោង៩ហ្នឹង
អើរដល់ពេលថ្ងៃល្ងាចហ្នឹងមកលេងផ្ទះឪពុកម្តាយឃើញទេ!!ដល់ពេលអូនអើយគេទៅចោល
អស់រលីងអាទូកមាស អ៊ីដើរមកជួបមេអាពត ជំនាន់អាពតហ្នឹង ដល់ពេលនេះដើរមកមុខគេ
គេអត់ហ៊ានធ្វើអីគេដែរអូន!!ម៉ោង៩ហា៎!!ប្រសិនម៉ោង២ ម៉ោង៣អ៊ី
គេសម្លាប់អ៊ីចោលមិនដឹងស្មើម៉ានផង។

ក៖គ្រាន់តែដើរកាត់មុខសោះហ្នឹង។

ខ៖ហ៊ឺ!!ចុះថាគេញថាអីទៅចុះ គេមិនថាយើងអញ្ចឹង គេញចោរអីវ៉ាន់អ៊ីចឹង
គេញចោរគេមិនបាញ់យើងចោល ចុះដើរហួសដែរ វាដើរហួសវាឃើញយើងវាអត់អីដែរ
ម៉ោងភ្លឺហើយ បើសិនណាម៉ោង១ម៉ោង២អញងាប់បាត់ហើយ
មិនដឹងម៉ែឪអញនៅឯណាទេលោកអើយ!!

ក៖អើយមីងហ្អើយ!!

ខ៖ចេះនឹកឃើញដែរជំនាន់ហ្នឹង នឹកឃើញកន្លែងហ្នឹងទឹកភ្នែកគេមកចោលអស់។

ក៖ញ៉ុមឮម៉ែញ៉ុមមកនិយាយប្រាប់ហា៎ពូញ៉ុមតែបន្តិចទេមីង គេយកទៅសម្លាប់ចោល!!

ខ៖ហ៊ឺ!!

ក៖ថ្ងៃហ្នឹងអ៊ីចឹងទៅណាស់!!

ខ៖ហ៊ឺ!!

កះហើយដល់ពេលអញ្ចឹងដើរទៅគេយកទៅហើយថាឃ្វាលគោអត់មើលគោ
ហើយគោហ្នឹងវាបោលមេឃភ្លៀងខ្លាំងហ្នឹងហើយអត់ដឹង!!

ខះមែនហើយដល់ពេលនេះចែកអោយពេលហ្នឹង អោយពួកយើងមើលគោអូនអើយ
យើងមើលគោអោយគេ មើលដល់គោជល់ គោជល់ត្រូវអ៊ីកន្លែងហ្នឹងរលាត់។

កះហើយស្នាមទាល់តែឥឡូវទេ?

ខះស្នាមទល់តែឥឡូវ។

កះមើលមើលបន្តិចមើល?

ខះហ៊ឺអ៊ីខ្ជិលអោយមើលណាស់។

កះអត់អីទេញ៉ុមស្មានតែនៅលើៗនេះ អ៉តអី។

ខះនៅស្នាមទល់តែឥឡូវ។

កះគោជល់ពីជំនាន់អាពត។

ខះស្នែងវាអោយស្រួចស្លែម ជល់២ ៣ត្រលប់ មើលគោអោយគេវេទនាណាស់អូនអើយ!

កះចា៎!!

ខះឥឡូវមកជំនាន់សប្បាយវិញហើយ។

កះហេងហើយជំនាន់ឥឡូវអត់មានមួយហ្នឹង បើពួកញ៉ុមហ្នឹងដឹងតែងាប់ម៉ង!!

ខះហ៊ឺ!!ពួកហ្អែងងាប់បាត់ហើយ។

កះពូញ៉ុមហ្នឹងហ្នឹមីងថ្ងៃហ្នឹងគេយកទៅសម្លាប់ចោលអ៊ីចឹងហើយគេហៅទៅហើយដល់ពេល
គាត់គេហៅអ៊ីចឹងទៅភ្លេច!!

ខះគេហៅទៅហ្នឹង គេហៅហ្នឹងយើងមិនដឹងខ្លួនទេអូន!!

កះចា៎!!

ខៈទៅដល់ចងសេក ចងខ្សែទាំងខ្សែទាំងខ្សែ។

កៈដើរវៃងាប់ទៅ? ហើយដល់ពេលហើយដើរទៅវង្វេងជាមួយអាពួកឆ្លបហ្នឹងហ្ន៎!!មីង!

ខៈហ៊ឺ!!

កៈពូញ៉ុមហ្នឹងហាំ!!វង្វេងជាមួយពួកឆ្លប។

ខៈអាខ្លះធ្វើងាប់ដែរតើអូន វ៉ៃចោលនៅក្នុងអន្លង់ធ្វើពុតធ្វើងាប់វាឡើងវិញដែរតើ!!!

កៈហ៊ឺ!!

ខៈដល់ពេលវាដើរទៅ ពូញ៉ុមហ្នឹងហ៊ិកន្លែងហ្នឹងហ៊ិ
គេដាក់ពូថៅហ្នឹងហាំ!!គេវ៉ៃយើងភូសភូសគេវ៉ៃយើងមិនចូលក្នុងអន្លង់។កៈចំ!!ខៈដល់ចូលអន្លង់ក៏ធ្វើងាប់ ដល់ពេលមេកងចេញវាឡើង ឡើងទៅរកកន្លែងមួយទៀតអ៊ីចឹង។

កៈអូយតែសុទ្ធតែប្រថុយខ្លាំងហើយមីងអើយ!!

ខៈហ៊ឺ!!ពុតធ្វើងាប់ហាំ!!

កៈហ្នឹងពូញ៉ុមហ្នឹងមីងដល់ពេលវង្វេងទៅ វង្វេងយប់ហ្នឹងបាត់ទៅ បាត់ទៅណាស់
ហើយដល់អញ្ចឹងមានតាមួយចាស់មួយហ្នឹងគាត់ថា
ហ្អែងហ្នឹងមែនអាពួកឃ្វាលគោ?ពួកអាឆ្លបមិញដើររកហាំ!!ហើយពួកគាត់រួចផុតទៅមីង!!

ខៈហ៊ឺ!!

កៈដល់ពេលស្អែកឡើងគាត់ទៅភូមិវិញ ទៅភូមិវិញគេថាបិតវគ្គវ៉ៃចោល គេឈប់វ៉ៃចោលទៅ
ហើយដល់ពេលអាឆ្លប់ហ្នឹងមកថាហ្អែងហារួចខ្លួនហ្អែង!! គេបិតវគ្គហ្នឹងចោល
!មីងអើយនិយាយពីថា!!តែឥឡូវពូញ៉ូមគាត់ធ្វើធំហើយ!!

ខៈនិយាយអាជំនាន់ហ្នឹងវេទនាណាស់!!ត្រូវហើយ។

កៈហេងណាស់មីងណាស់!!

ខៈហេង។

ក៖ហ្នឹងហើយ អ៊ីចឹងមីងសល់ប្រហែលជាមួយសំនួរទៀតអីវ៉ាន់ទេ អត់សួរយូរទៀតទេ!!អ៊ីចឹងដោយសារមីងមានកូនមានអីហើយមែនទេមីង?

ខ៖មាន។

ក៖ចាំ!!អូមិញឈប់បន្តិចទៀតសិនបន្ទាប់ពីបែកប៉ុល ពតមកមីងរៀបការមកម៉ងហោ?

ខ៖ហ្នឹងហើយ។

ក៖ហើយពេលរៀបការមកពេលអ្នកមីងបែកមកមីងរកស៊ីអីគេដែរ?

ខ៖រកស៊ីធ្វើអីអូនធ្វើតែស្រែចំការហ្នឹង!!

ក៖តែស្រែចំការហ្នឹងទេ!!ហើយចុះមានកូនអីវ៉ាន់ហ្នឹងពេលមានកូនមកហ្នឹងមីងមានអោយកូនរៀនអត់?

ខ៖រៀន!!

ក៖ទាំង៣នាក់ហ្នឹងអោយរៀនទាំង៣ទេ?

ខ៖រៀនទាំង៣ហ្នឹង។

ក៖ចាំ!!

ខ៖ហើយឈប់រៀនអស់ហើយអូន ឈប់រៀនអស់ហើយ ចេះរៀនបានថ្នាក់ទី៨ ទី៨ទី៩ហ្នឹងហាំ!!

ក៖ចាំ!!

ខ៖យើងរកស៊ីអស់ហើយយើងរៀនតអីទៀត ទៅរៀនម៉ាស៊ីនត្រជាក់នៅកំពង់សោមហ្នឹង សប្បាយវាអស់ទាស់ហើយ។

ក៖ហ្ហ៎អ៊ីចឹងទៅរៀនចាប់ជំនាន់វិញ?

ខ៖ហ្នឹងហើយវាទៅរៀនម៉ាស៊ីនត្រជាក់។

កៈចាំ!!ហ្នឹងហើយ។អ៊ីចឹងបានចាប់ជំនាញទៅរៀងល្អបន្តិចហើយមីងណោះ?

ខៈហ៊ឺ អាមួយហ្នឹងគេស្រលាញ់វាចង់ងាប់។

កៈចាំ!!ចុះកូនស្រីៗពីរនាក់ទៀត?

ខៈអាអូននៅផ្ទះនៅចាំផ្ទះ។

កៈហើយមីងអត់អោយ!!គាត់ឈប់រៀនខ្លួនឯងឬក៏គាត់ឈប់?

ខៈវាឈប់ខ្លួនឯង!!

កៈហ្អ៊ូ!!

ខៈទៅរៀនកាលភ្ជុំហ្នឹងទៅរៀនទិញកាតាបទិញអីអោយរៀនទៀតវាអត់រៀន!!
រៀនធ្វើអីរៀនបានធ្វើអីយើងនៅតែធ្វើស្រែដដែល។

កៈមីងតស៊ូបន្តិចទៅ!!ដ

ខៈរៀនល្មមបានហើយ!!ចេះល្មមៗបានហើយ!!

កៈចាំ!!

ខៈកូនវាអោយរៀនទៀតហើយ តែវាអត់រៀន។

កៈអ៊ីចឹងអ្នកមីងសំរាប់ចំនង់ចំនូលចិត្តអ្នកមីងអ្នកមីងចូលចិត្តញុំាម្ហូបអីគេ?ខៈចាំ?កៈមីងចូលចិត្តញុំាម្ហូបអីគេដែរ?

ខៈហ៊ឺមានអីសាច់ជ្រូកត្រីហ្នឹងអូន!!

កៈចាំ!!ម្ហូបដែលមីងចូលចិត្តជាងគេដែលមីងចូលចិត្តជាប្រចាំនៅក្នុងគ្រួសារធ្វើអីគេច្រើនជាងគេ?

ខៈហ្អ៊ូ គ្រប់មុខហ្នឹងអូនអើយមិនរើសទេ។

កៈសំលម្ជូរ ប្រហុកអីវ៉ាន់ទៅហី!!

ខះម្ទូរអីវ៉ាន់ទៅ
ត្រូវចិញ្ច្រាំប្រហុកចិញ្ច្រាំប្រហុកអីចឹងទៅអន្លក់អីចឹងទៅដូចតែគ្នា។កះចាំ!!ខះបើមានបើមានលុយទិញគេ ស្អីក៏ចូលចិត្តដែរ។

កះអីចឹងអ្នកមីងដើម្បីអោយក្រុមគ្រួសារអ្នកមីងមានសុភមង្គលអ្នកមីងបានលះបង់អីគេដែរសំរាប់ជួយដល់ក្រុមគ្រួសារក៏ដូចជាតើអ្នកមីងមានចិត្តម៉េចដែរដើម្បីអោយក្រុមគ្រួសារអ្នកមីងមានសុភមង្គល?ពេលខឹងគ្នាអីវ៉ាន់ម៉េចដែរមីង?ចេះអត់ចេះអីម៉េចដែរ?

ខះចេះអត់អោនគ្នាអូន!!កះចាំ!!ខះយើងតែគេមាត់ធំដាក់យើងយើង នៅនេះទៅ
យើងកុំប្រឆាំងគេ ប្រឆាំងទំរាំតែឈ្លោះគ្នា ប៉ុន្តែមិនដែល ប៉ុន្តែលេងសើចច្រើន។

កះប្តីលេងសើចច្រើនហេ?

ខះលេងសើចច្រើន។

កះហ៊ីបានអញ្ចឹងទៅអត់ស្ងួរអផ្សុកមីងហាំ!!

ខះអត់ចេះហូបស្រាទេ។

កះចាំល្អហើយអញ្ចឹង។

ខះអោយធ្វើបង្អែមហូប។

កះធ្វើបង្អែមហូបវិញ?

ខះអត់ចេះស្រា អត់ចេះទេ។

កះគាត់ជ្រើសរើសត្រូវហើយអ្នកមីងដោយសារការហូបស្រា
មីងគិតមើលមើលប៉ះពាល់សុខភាពហើយអស់ទាំងលុយទៀត។

ខះអស់លុយទៀត!

កះហើយហូបទៅវេទនាមិនមែនស្រួលទេណាស់!!ផឹកទៅថ្មិចភ្នែកទៀតហាំ!!

ខះហ្នឹងហើយ អាប្រពន្ធកូនមានយកទៅអោយគេង៉ែងសប្បាយចាយធ្វើអី អញតែ២០០០០ទៅពីរនាក់ប្តីប្រពន្ធអញទៅស៊ីមួយទំហឹង អត់អោយង៉ែងចាយអាលីអាឡឺ គិតណាស់ប្តីញ៉ូម!!

កះអូយល្អណាស់មីងអឺចឹងបានស្វាមីក្មេងហើយចេះគិតគូរគ្រួសារទៀត។ហេសំណាងណាស់ហិ!!

ខះគេថាញ៉ុមសំណាងគ្រប់គ្នា។

កះចាំហ្នឹងហើយ។អឺចឹងអ្នកមីងមួយនេះគឺជាសំនួរមួយចុងក្រោយចប់ហើយការសំភាសន៍មីងមានពាក្យពេចន៍អីចង់ផ្តែផ្តាំទៅកាន់កូនចៅជំនាន់ក្រោយអឺចឹងហាំចៅៗមីងអឺចឹងហាំចង់អោយគាត់ដើរលើផ្លូវម៉េចដែរហើយចង់អោយគាត់ជាមនុស្សម៉េចដែរអឺចឹងហាំមីងហាំ?

ខះអោយកូនចៅយើងដើរល្អអឺចឹងទៅធ្វើល្អអឺចឹងទៅយើងកុំថា វាមានមិត្តភក្តិអឺចឹងទៅទៅជួបទៅស៊ីកូនញ៉ុមណែនាំថាដើរតាមគេអត់ចូលចិត្តដើរលេងទេនៅកន្លែងធ្វើការទេ!!

កះចាំ!!

ខះហើ យផ្តាំថាអោយខំប្រឹងរកលុយរកកាក់អីគេអឺចឹងទៅ យើងមានលុយ យើងស្រលាញ់កូនគេរកកន្លែងហ្នឹងបានហើយឃើញទេ យើងក្រគេមើលងាយយើងទៀត។

កះហ្នឹងហើយត្រូវតែអឺចឹងម៉ង។

ខះតែយើងមានលុយយើងទៅណាយើងទៅដណ្តឹងប្រពន្ធក៏គេអោយយើងដែរមែនទេនេះមួយសារហើយនេះគេអោយតែយកកទៅដើរលេងសើចអីវ៉ាន់គេអោយយើងមែន!!វាចេះណាស់ឥឡូវហ្នឹងអើយ!!មាំណាស់កូនប្រសារ។

កះចាំ!!

ខះអឺចឹងបើម្នាក់ហ្នឹងផឹកស្រាស្មាអី គេមិនអោយកូនទេ។

ខះអ្នកណាគេអោយកូនអីគេអូន!!

កះ ចាំហ្នឹងហើយ។

ខះចរិកកូនខ្ញុំហាំតាំងពីទូចតាំងពីអាយុ៨ឆ្នាំដើរកាន់គោយន្តតាំងពីអាយុ៨ឆ្នាំហាំ??

កះដើរកាន់អីគេ?

ខះគោយន្ត។

កះគោយន្ត ហ៊ុឡូយម្លេះ!!

ខះ៨ឆ្នាំហាំ!!

កះចា!!ដល់ប៉ាគេឃើញឯងមើលកូនណោះកាន់ដៃមើលធ្វើមិនដឹង ស្រលាញ់កូនញ៉ុមណាស់ កូនញ៉ុមប្រុសតែមួយហ្នឹងស្រលាញ់ណាស់។

កះចាំហ្នឹងហើយ។

ខះដើរតែរកលុយកាក់អោយម៉ែម៉ែ !!អូនហាម៉ែខ្ញី២០០មកម្លេះមកផ្លុស !!

កះហ៊ីៗ!!

ខះមើលចូលឆ្នាំទិញនិចអោយវា។

កះទិញអីគេអោយ?

ខះទិញនិច។

កះម៉ូតូហេ?

ខះម៉ូតូនិច គេស្រលាញ់អានិចគេ។

កះម៉ូតូនិច!!

ខះគេមកពីម្សិលម៉ែនិចហាំម៉ែហាំ!!ហ្អែងអើយហាំ!!ទិញអានិច
អត់ទេញ៉ុមមានខ្លះម៉ែឯងមានខ្លះមក ញ៉ុម១០០០ម៉ែឯងចេញតែ៤០០អោយបានហើយ!!

កះហ៊ីល្អណាស់ហិ!!គេចេះសន្សំលុយសន្សំអីទៀតមីងណោះ!!

ខ៖មួយសារអ៊ីចឹងទៅ
មុនញ៉ុមទិញចិញ្ចៀនអោយភ្ជុំទិញចិញ្ចៀនដល់ពេលចូលឆ្នាំសារហ្នឹងអើរទិញខ្សែករឥលូវឆ្នាំហ្នឹងទិញថាទិញផ្កាកដៃអោយវាតែម៉ូតូនិចទៀត។

ក៖ចាំ ហោចេះរកស៊ី។

ខ៖បើតាមទូរន្ទានញ៉ុមស្រលាញ់កូនណាស់។

ក៖ចាំហ្នឹងហើយ

ខ៖ ស្រលាញ់កូនទាំងអស់។

ក៖ចាំ!!អ៊ីចឹងអរគុណច្រើនអ្នកមីងសំរាប់ការសំភាសន៍នៅក្នុងថ្ងៃនេះ
រៀងមួយសន្ទុះធំហើយមីងហោ!!អ៊ីចឹងអរគុណច្រើនអ្នកមីងសំរាប់ការសំភាសន៍អំពីជីវប្រវត្តិរបស់អ្នកមីងចាំ។